ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២៨០/១៣-ម៉ាវ ស៊ុន (ខេមបូឌា) ហ្គាមេន ខូអិលធីឌី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **សុខ ម៉ាធឿង**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ម៉ាវ ស៊ុន (ខេមបូឌា) ហ្គាមេន ខូអិលធីឌី**

អាសយដ្ឋាន ៖ ភូមិអង្គតាកៀត សង្កាត់កន្ទោក ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៦៧១ ៥៧១ ទូរសារ ៖ គ្មាន

-តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ ៖ **អវត្តមាន**

-តំណាងភាគីនិយោជកចូលរួមសវនាការលើកទី២ ៖ **អវត្តមាន**

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖- **សហព័ន្ធសហជីពដើម្បីសិទ្ធិការងារ**

អាសយដ្ឋាន ៖ ភូមិអង្គតាកៀត សង្កាត់កន្ទោក ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៥៤៩ ៩៤៥ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១ ៖

- លោក សំ វិសូ មន្ត្រីសហព័ន្ធសហជីព UFLR
- លោក សំ ផានិត អនុប្រធានសហព័ន្ធសហជីព TUFW

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១ ៖ អវត្តមាន

- **សហព័ន្ធសហជីពប្រជាធិបតេយ្យសំណាងកម្មករ**
- **សហព័ន្ធសហជីពពលកម្មកម្ពុជា**
- **សហព័ន្ធសហជីពសន្តិភាពដើម្បីកម្មករ**
- **សហព័ន្ធសហជីពសម្លេងកម្មករកម្ពុជា**
- **សហព័ន្ធសហជីពគាំទ្រកម្មករកម្ពុជា**

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី២ ៖ អវត្តមាន

- **សហព័ន្ធសហជីពដើម្បីសិទ្ធិការងារ**
- **សហព័ន្ធសហជីពប្រជាធិបតេយ្យសំណាងកម្មករ**
- **សហព័ន្ធសហជីពពលកម្មកម្ពុជា**
- **សហព័ន្ធសហជីពសន្តិភាពដើម្បីកម្មករ**
- **សហព័ន្ធសហជីពសម្លេងកម្មករកម្ពុជា**
- **សហព័ន្ធសហជីពគាំទ្រកម្មករកម្ពុជា**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនដកអ្នកគ្រប់គ្រងជនជាតិចិន ហៅយាយវ៉ែនតា ចេញពីការងារ ព្រោះគៀបសង្កត់កម្មករខ្មែរ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចដកអ្នកគ្រប់គ្រងជនជាតិចិន ចេញពីការងារបានទេ ហើយក្រុមហ៊ុននឹងអប់រំណែនាំគាត់ទៅតាមបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩៥ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៦៥៣ កប/អក/វក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣។

**សវនាការ និង សន្ទេបនីតិវិធី**

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ " ។

**កាលបរិច្ឆេទសវនាការ** ៖ - លើកទី១ ៖ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៤ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល ) ។

- លើកទី២ ៖ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល ) ។

**សវនាការ និង សន្ទេបនីតិវិធី**

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងពីនាយកក្រុមហ៊ុនស្តីពីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ដោយទទួលបាន លទ្ធផលសះជានឹងគ្នាចំនួន ១១ចំណុច និងមិនសះជានឹងគ្នាចំនួន ០១ ចំណុច លើការទាមទារចំនួន ១២ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ១៦៥៣ កប/អក/វក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០១៣។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតដែលមានសហព័ន្ធចំនួន ០៦ គឺ ១)សហព័ន្ធសហជីពដើម្បីសិទ្ធិការងារ, ២)សហព័ន្ធសហជីពប្រជាធិបតេយ្យសំណាងកម្មករ ៣)សហព័ន្ធសហជីពពលកម្មកម្ពុជា, ៤)សហព័ន្ធសហជីពសម្លេងកម្មករកម្ពុជា, ៥)សហព័ន្ធសហជីពសន្តិភាពដើម្បីកម្មករ និង ៦)សហព័ន្ធសហជីពគាំទ្រកម្មករកម្ពុជា មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤ វេលាម៉ោង ២៖០០ នាទីរសៀល។ សវនាការនេះត្រូវបានពន្យារទៅថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៤ វេលាម៉ោង ២៖០០នាទី រសៀល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ មានកម្មករនិយោជិតចំនួន ១៣ នាក់ បានផ្ទេរសិទ្ធិឱ្យសហព័ន្ធទាំង០៦ ក្នុងការដោះស្រាយឱ្យពួកគាត់។

នៅថ្ងៃសវនាការទី២ សហព័ន្ធចំនួន ០៣ ដែលរួមមាន៖ សហព័ន្ធសហជីពដើម្បីសិទ្ធិការងារ, សហព័ន្ធសហជីពប្រជាធិបតេយ្យសំណាងកម្មករ និង សហព័ន្ធសហជីពសម្លេងកម្មករកម្ពុជា បានសម្រេចដកពាក្យបណ្តឹង។ ដោយឡែក សហព័ន្ធសហជីពចំនួន ០៣ ទៀត គឺសហព័ន្ធសហជីពសន្តិភាពដើម្បីកម្មករ, សហព័ន្ធសហជីពគាំទ្រកម្មករកម្ពុជា និងសហព័ន្ធសហជីពពលកម្មកម្ពុជា និងភាគីនិយោជកមិនបានចូលរួមសវនាការអាជ្ញាកណ្តាលតាមការកោះអញ្ជើញ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេចដូចខាងក្រោម ៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ម៉ាវ ស៊ុន (ខេមបូឌា) ហ្គាមេន ខូអិលធីឌី លេខ ១៦៥៣ កប/អក/វក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ម៉ាវ ស៊ុន (ខេមបូឌា) ហ្គាមេន ខូអិលធីឌី ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៣៩៣ កប/អក/វក/លកអ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៣៩៤ កប/អក/វក/លកអ. ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ០៣២ កប/អក/វក/លកអ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លើកទី២ លេខ ០៣៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងនឹងការទាមទារ នៅក្នុងសំណុំរឿងនេះទេ ដោយហេតុថា នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិត (សហព័ន្ធសហជីពសន្តិភាពដើម្បីកម្មករ, សហព័ន្ធសហជីពគាំទ្រកម្មករកម្ពុជា និងសហព័ន្ធសហជីពពលកម្មកម្ពុជា) និងភាគីនិយោជក មិនបានអញ្ជើញមកចូលរួមសវនាការអាជ្ញាកណ្តាលទេ ហើយក៏មិនបានផ្តល់នូវមូលហេតុត្រឹមត្រូវណាមួយឡើយ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះដែរ ឬទេ ខណៈដែល ភាគីកម្មករនិយោជិត (សហព័ន្ធសហជីពសន្តិភាពដើម្បីកម្មករ, សហព័ន្ធសហជីព

គាំទ្រកម្មករកម្ពុជា និងសហព័ន្ធសហជីពពលកម្មកម្ពុជា) និងភាគីនិយោជក មិនបានមកចូលរួមសវនាការអាជ្ញាកណ្តាល ?

ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់ "* ។

បន្ថែមពីនេះទៀត វិធាន ៤.៧ នៃវិធាននីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា៖ *"ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាង ក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់ ។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាល ត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន "* ។

ផ្អែកលើប្រការ ២១ និងវិធាន ៤.៧ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បានបកស្រាយថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញ មុនពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ។ លក្ខខណ្ឌទី២ គឺភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន។ (សូមមើលក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៣០/០៥-មូរៀ, លេខ ១៦/០៧-ឡូទូសតី, លេខ ២៧/០៧-អ៊ឹម និង វ៉េ ៣, លេខ ៩៥/០៨-យ៉ុង វ៉ា ទី១, លេខ ១៣២/០៨-ជី អេច ជី, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១៥១/០៨-វិល សិន, លេខ ០៩/០៩-នីមបឹស ចិចថាយ៍, លេខ ០១/១០-ខិននីតិច,លេខ ៣០/១០-កូប័ល អាប៉ារ៉ែល, និងលេខ ២១២/១៣- ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល*)

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការរកឃើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ ។

ដូច្នេះ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើលក្ខខណ្ឌទាំងបីត្រូវបានបំពេញដែរឬទេ?

**លក្ខខណ្ឌទី ១ ៖ ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើលិខិតអញ្ជើញលាយលក្ខណ៍អក្សរជាផ្លូវការ ទៅកាន់ភាគីទាំងពីរដើម្បីចូលរួមសវនាការអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងនេះ។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើលិខិតអញ្ជើញទៅកាន់ភាគីនិយោជកតាមរយៈលិខិត លេខ ០៣២ កប/អក/វក/លកអ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤ និងទៅកាន់ភាគីកម្មករនិយោជិត តាមរយៈ លិខិតលេខ០៣៣

កប/អក/វក/លកអ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤ ។ លិខិតអញ្ជើញទាំងនេះ ត្រូវបានធ្វើឡើងតាមនីតិវិធីជាប្រចាំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយបានបញ្ជាក់អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងច្បាស់លាស់នៃសវនាការអាជ្ញាកណ្តាល ហើយមន្រ្តីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានទាក់ទងតាមទូរស័ព្ទទៅកាន់ភាគីនិយោជក និង ភាគីកម្មករនិយោជិតឱ្យមកយកលិខិតអញ្ជើញនេះ និងបានបញ្ជាក់អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងច្បាស់លាស់នៃសវនាការអាជ្ញាកណ្តាលដែរ ។ នៅថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៤ តំណាងសហភាពពលកម្មជាតិកម្ពុជា និង តំណាងសហព័ន្ធសហជីពដើម្បីកម្មករបានមកយកលិខិតអញ្ជើញនេះ ហើយតំណាងសហព័ន្ធសហជីពសទ្ធិភាពដើម្បីកម្មករ និង ពលកម្មកម្ពុជា បានមកទទួលលិខិតអញ្ជើញ នៅថ្ងៃទី០៩ ខែ មករា ឆ្នាំ២០១៤ ។ ដោយឡែកសហព័ន្ធសហជីពគាំទ្រកម្មករកម្ពុជា មិនបានមកទទួលលិខិតអញ្ជើញដោយផ្ទាល់ទេ។ ចំណែកឯភាគីនិយោជកវិញ មិនបានមកទទួលយកលិខិតអញ្ជើញនេះដោយផ្ទាល់ពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។

បន្ថែមលើនេះ នៅថ្ងៃសវនាការ មន្រ្តីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានធ្វើទំនាក់ទំនងតាមទូរស័ព្ទទៅកាន់ភាគីកម្មករនិយោជិត និងភាគីនិយោជក ដើម្បីអញ្ជើញមកចូលរួមសវនាការអាជ្ញាកណ្តាលផងដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីទាំងពីរត្រូវបាន ជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងច្បាស់លាស់ នៃសវនាការអាជ្ញាកណ្តាលដោយ លេខាធិការដ្ឋានក្រុមប្រឹក្សា អាជ្ញាកណ្តាល។

ដូចនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ២ ៖ ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យ *"បង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល"* នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ខាងលើ មានន័យថា ភាគីត្រូវតែ ១) មានវត្តមាននៅក្នុងសវនាការ និង២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាល តាំងពីដើមរហូតដល់ចប់សព្វគ្រប់។

ដំណើរការសវនាការអាជ្ញាកណ្តាល ដែលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ និង

ឃ-ដំណាក់កាលសវនាការដល់អង្គសេចក្តី

បន្ថែមលើនេះ ប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា៖ *"ភាគីវិវាទអាចមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយ មានអ្នកអម ឬតំណាងដោយមេធាវីដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គល ផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"* ។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជក និងភាគីកម្មករនិយោជិត មិនមានវត្តមាននៅថ្ងៃសវនាការអាជ្ញាកណ្តាលទេ ហើយក៏មិនបានចាត់ឱ្យមានអ្នកតំណាងត្រឹមត្រូវតាមរយៈការអនុញ្ញាតជាលាយលក្ខណ៍អក្សរណាមួយ

ដើម្បីតំណាងឱ្យភាគីទាំងពីរនៅក្នុងសវនាការអាជ្ញាកណ្តាលនោះដែរ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។

**លក្ខខណ្ឌទី ៣ ៖ *ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន***

ក្នុងករណីនេះ ភាគីនិយោជក និងភាគីកម្មករនិយោជិត (សហព័ន្ធសហជីពសន្តិភាពដើម្បីកម្មករ, សហព័ន្ធសហជីពគាំទ្រកម្មករកម្ពុជា និងសហព័ន្ធសហជីពពលកម្មកម្ពុជា) បានអវត្តមាននៅក្នុងសវនាការអាជ្ញាកណ្តាល។ នៅថ្ងៃសវនាការ នាថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ វេលាម៉ោង ២៖១១ នាទីរសៀល មុនពេលកំណត់នៃការចាប់ផ្តើមសវនាការ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើទំនាក់ទំនងតាមទូរស័ព្ទទៅកាន់ភាគីនិយោជក និងភាគីកម្មករនិយោជិត ឱ្យមកចូលរួមសវនាការអាជ្ញាកណ្តាល។ ភាគីនិយោជក បានប្រាប់មកមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ភាគីនិយោជកមិនអាចមកចូលរួមក្នុងសវនាការបានទេ។ ប្រធានសហព័ន្ធសហជីពពលកម្មកម្ពុជា បានប្រាប់មកមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា "*ក្រុមហ៊ុនមិនអនុញ្ញាតឱ្យសហជីពមូលដ្ឋានចេញមកចូលរួមសវនាការទេ*"។ បន្តិចក្រោយមក មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការទាក់ទងតាមទូរស័ព្ទម្តងទៀត ប៉ុន្តែមិនអាចទាក់ទងបាន។ នៅថ្ងៃសវនាការដដែល វេលាម៉ោង ២៖ ១៧ នាទីរសៀល មន្ត្រីសហព័ន្ធសហជីពសន្តិភាពដើម្បីកម្មករ បានប្រាប់មកមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា គាត់បានប្រាប់ទៅកម្មករអំពីកាលបរិច្ឆេទថ្ងៃសវនាការ តែគាត់ភ្លេចមិនចាំថ្ងៃសវនាការ ចាំគាត់សួរទៅសហជីពមូលដ្ឋាន ថាតើមានសហជីពមូលដ្ឋានអាចចូលរួមសវនាការបានដែរឬអត់? បន្តិចក្រោយមក គាត់បានបញ្ជាក់ថា "*អត់មានអ្នកមកទេ*"។ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចទាក់ទងសហព័ន្ធសហជីពគាំទ្រកម្មករកម្ពុជាបានទេ ដោយសារមិនអាចទាក់ទងតាមរយៈទូរស័ព្ទបាន។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីទាំងពីរមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការ មិនបង្ហាញខ្លួននៅក្នុងសវនាការអាជ្ញាកណ្តាលទេ។ ហេតុនេះ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ នៅក្នុងសំណុំរឿងនេះ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាល នៃសំណុំរឿងលេខ ២៨០/១៣- នេះ ដោយសារភាគីនិយោជក និងភាគីកម្មករនិយោជិត (សហព័ន្ធសហជីពសន្តិភាពដើម្បីកម្មករ, សហព័ន្ធសហជីពគាំទ្រកម្មករកម្ពុជា និងសហព័ន្ធសហជីពពលកម្មកម្ពុជា) អវត្តមាន នៅពេលសវនាការអាជ្ញាកណ្តាល។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ២៨០/១៣-ម៉ាវ ស៊ុន (ខេមបូឌា) ហ្គាមេនខូអិលធីឌី។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **អ៊ឹង សុទ្ធី**

ហត្ថលេខា ៖ -----------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ -----------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **សុខ ម៉ាឡឿង**

ហត្ថលេខា ៖ -----------------------------------